ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា
ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ

# សេចក្តីជូនដំណឹង
## ស្តីពី នីតិវិធីនៃការទទួលបានភាពស្របច្បាប់របស់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦

យោងលទ្ធផលកិច្ចប្រជុំជាមួយក្រសួងការងារថៃ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៦ កន្លងទៅនេះ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជូនដំណឹងដល់សាធារណជន ជាពិសេសពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបថា៖

- ក្រសួងការងារថៃ នឹងធ្វើការផ្សព្វផ្សាយអំពីបញ្ជីឈ្មោះពលករកម្ពុជា ដែលមានលិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) និងប័ណ្ណព័ណ៌ស៊ីជំពូ ចំនួនសរុប ១៩៨,៩៣០នាក់ ក្នុងគេហទំព័ររបស់ក្រសួងការងារថៃ និងនាយកដ្ឋានមុខរបរថៃ ហើយនឹងចាប់ផ្តើមឱ្យដំណើរការប្រព័ន្ធ Online សម្រាប់ឱ្យពលករកម្ពុជា និងនិយោជកថៃ ស្នើសុំដកលិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) ពីភាគីកម្ពុជា តាមរយៈនាយកដ្ឋានមុខរបរថៃ ឬមន្ទីរការងារថៃ ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦ តទៅ។
- ក្រសួងការងារថៃ នឹងជូនដំណឹងជាផ្លូវការអំពីកម្រៃសេវាបើកផ្តល់លិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) នៅក្រៅប្រទេស ចំនួន ៩៥០បាត និងនីតិវិធីលម្អិតនាចុងខែសីហានេះ។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៦